**លោកជំទាវ ឯកឧត្តម លោក លោកស្រី ជាទីគោរពរាប់អាន**

ក្នុងនាមខ្ញុំគណៈកម្មការទី៣ នៃរដ្ឋសភាដែលទទួលបន្ទុក ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និង ធនធានទឹក ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានអញ្ជើញចូលរួម ក្នុងឱកាសនៃការបើកកិច្ចពិភាក្សាតុមូលដ៏មានសារៈសំខាន់ ស្តីពី "ស្ថានភាពជាក់ស្តែង និងសក្តានុពល នៃផលិតផលកសិកម្ម និងជលផល ឆ្នាំ២០០៥-២០០៦ " ដែលរៀបចំឡើងដោយ **វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC)** ក្រោមការឧបត្ថម្ភ និងគាំទ្រពី**គម្រោងគាំទ្រនីតិប្បញ្ញត្តិកម្ពុជា-កាណាដា (CCLSP)** នៅសណ្ឋាគារកាំបូឌីយ៉ាណានាថ្ងៃនេះ។

ជាបឋម ខ្ញុំសូមកោតសសើរដោយស្មោះ និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **បងបណ្ឌិត សុក ហាច** នាយកវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា និង **បង ម៉ែន ម៉ុនឡេង** នាយកគម្រោងគាំទ្រ នីតិប្បញ្ញត្តិកម្ពុជា-កាណាដា ដែលបានរៀបចំនូវកិច្ចពិភាក្សាពិគ្រោះយោបល់ ដ៏មានសារៈសំខាន់នេះឡើង។

ខ្ញុំមានជំនឿថា វេទិកានៃកិច្ចពិភាក្សាតុមូលនាថ្ងៃនេះ ពិតជាផ្តល់ឱកាសមួយយ៉ាងល្អប្រពៃ និងផ្តល់នូវគំនិត និងអនុសាសន៍ល្អៗ ដើម្បីចូលរួមនៅក្នុងការអភិវឌ្ឍវិស័យកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង។

វត្តមានដ៏ឧត្តុង្គឧត្តមរបស់ លោកជំទាវ ឯកឧត្តម លោកស្រី លោក នៅក្នុងវេទិកានេះ ជាការបង្ហាញឱ្យឃើញនូវការយកចិត្តទុកដាក់ចំពោះវិស័យកសិកម្មកម្ពុជា ជាពិសេសចំពោះសក្តានុពលភាព នៃដំណាំកសិ-ឧស្សាហកម្ម និងធនធានជលផលសំដៅជំរុញការនាំចេញ ហើយវាក៏ជាវេទិកាមួយយ៉ាងល្អ ដើម្បីផ្សព្វផ្សាយ ជម្រាបជូនថ្នាក់ដឹកនាំ មន្ត្រីពាក់ព័ន្ធ អ្នកស្រាវជ្រាវ អ្នកវិនិយោគទុនទាំងអស់ ឱ្យបានជ្រាប និងចូលរួមលើកតម្កើងសក្តានុពលភាពកសិកម្ម និងជលផលកម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ឱ្យបានរីកចំរើនដូចបណ្តាប្រទេសអភិវឌ្ឍន៍នានា។

**លោកជំទាវ ឯកឧត្តម លោកស្រី លោក**

ចំពោះព្រះរាជាណាចក្រកម្ពុជាយើង វិស័យកសិកម្ម គឺជាវិស័យអាទិភាព និងមានសក្តានុពលភាពខ្ពស់ នៅក្នុងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ចជាតិទាំងមូល។

តាមគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ MDGs ប្រទេសកម្ពុជាត្រូវកាត់បន្ថយអត្រានៃភាពក្រីក្រឱ្យបានពាក់កណ្តាលនៅក្នុងឆ្នាំ២០១៥ ដែលអត្រានៃភាពក្រីក្រ នៅឆ្នាំ១៩៩៣ មាន ៤៧% នេះបើយោងទៅតាមតួលេខរបស់ធនាគារ ពិភពលោក។

ហើយបើយើងអានរបាយការណ៍ ស្ដីពីការវាយតម្លៃពីភាពក្រីក្ររបស់ធនាគារពិភពលោក គេបានបញ្ជាក់ផងដែរថា អត្រានៃភាពក្រីក្ររបស់កម្ពុជា នឹងអាចកាត់បន្ថយមកនៅត្រឹម ២៨% បើសិនជាវិស័យកសិកម្មមានកំណើន ៣% ក្នុងមួយឆ្នាំ ធៀបទៅនឹងកំណើននៃ ផលិតផលក្នុងស្រុកសរុបដែលមាន ៧% ក្នុង ១ឆ្នាំ។

ផ្ទុយទៅវិញ អត្រានៃភាពក្រីក្រនៅទូទាំងប្រទេស នឹងអាចធ្លាក់មកនៅត្រឹមតែ ២១% នៅក្នុងឆ្នាំ ២០១៥ បើសិនជាវិស័យកសិកម្មមានការរីកចំរើន ៤% ក្នុងមួយឆ្នាំ ធៀបទៅនឹងកំណើនសេដ្ឋកិច្ចដូចគ្នាគឺ ៧%ក្នុងមួយឆ្នាំនោះ។

នេះបញ្ជាក់ថា អត្រានៃភាពក្រីក្រ នៅក្នុងប្រទេសកម្ពុជា នឹងកាន់តែមានកំរិតទាប បើសិនជាវិស័យកសិកម្មមានការរីកចំរើនកាន់តែខ្លាំ។

ដូច្នេះវិស័យកសិកម្មមានតួនាទីសំខាន់ណាស់ នៅក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រនៅទូទាំងប្រទេស ហើយម្យ៉ាងទៀត វិស័យនេះ ក៏ជាប្រភពចំណូលដ៏សំខាន់របស់ប្រជាពលរដ្ឋខ្មែរ ពិសេសប្រជាកសិករដែល រស់នៅតាមតំបន់ជនបទ។

ជាការពិតណាស់ បើយើងគិតដល់វិស័យកសិកម្ម មានកត្តាជាប់ទាក់ទងជាច្រើនដូចជាធនធាន ធម្មជាតិ ព្រៃឈើ ការផ្គត់ផ្គង់ និងការគ្រប់គ្រងធនធានទឹក ការគ្រប់គ្រង និងការប្រើប្រាស់ដី និង ជី ការដាំដំណាំចំរុះ ការចិញ្ចឹមសត្វ ការនេសាទ ។ល។

ប្រជាពលរដ្ឋកម្ពុជា ៨៥% រស់នៅតាមជនបទភាគច្រើនជាកសិករប្រកបរបរកសិកម្មតាំងពីបុរាណកាលមក ប្រជាពលរដ្ឋលោកយល់ច្បាស់ពីការដាំដំណាំកសិកម្ម។

ហើយបើតាមខ្ញុំបានដឹង ដោយពឹងផ្អែកលើត្រី និងស្រូវនេះហើយ ដែលបុព្វបុរសខ្មែរបុរាណយើងបានកសាង អង្គរវត្តដ៏ល្បីល្បាញលើពិភពលោក។

កង្វះខាតស្បៀងអាហារជាការព្រួយបារម្ភបំផុត និងជាការប្រឈមមុខមួយដ៏សំខាន់របស់យើង ក៏ដូចជាពិភពលោក ខណៈពេលដែលកសិផលផ្ដល់ឱ្យតាមទំហំផ្ទៃដី និងទិន្នផលនៅមានកំរិតទាប ចំណែកចំនួនប្រជាពលរដ្ឋវិញ បានកើនឡើងជារៀងរាល់ថ្ងៃ បណ្ដាលឱ្យមានកំណើននៃតំរូវការអាហារប្រចាំថ្ងៃកាន់តែខ្ពស់ឡើងៗ។

ដោយហេតុនេះ អគ្គលេខាធិការ អង្គការសហប្រជាជាតិ បានដាក់ចេញនូវដំណោះស្រាយស្ដីពីសុវត្ថិភាពស្បៀងអាហារ លើពិភពលោក។

ប្រទេសយើង មានកសិផលជាច្រើនប្រភេទ ដែលមានសក្តានុពលភាពនាំចេញទៅលក់នៅក្រៅប្រទេសដូចជា ការ៉ុត ដំឡូង ប៉េងប៉ោះ ខ្ទឹមបារាំង និងផលិតផល ជលផលជាច្រើន រួមទាំងក្រពើជាដើម ។

ប៉ុន្តែខ្ញុំយល់ថា យើងនៅមានចំនុចខ្សោយមួយចំនួន ដែលយើងពុំអាចនាំចេញឱ្យអស់តាមសក្តានុពលភាព និងលទ្ធភាពរបស់យើង ដោយយើងនៅមានកំរិតបច្ចេកវិទ្យាដែលបរិមាណ និងគុណភាពកសិផលពុំទាន់ឆ្លើយតបបានតាមតំរូវការទីផ្សារអន្តរជាតិនៅឡើយ ។

យើងត្រូវរកទីផ្សារផលិតផល ស្តារប្រព័ន្ធធារាសាស្ត្រ និងកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀតជាអាទិភាព ដើម្បីសម្រួល និងជម្រុញការងារនេះ ។

ការអនុវត្តការដាំដុះនៅជាលក្ខណៈគ្រួសារ មានគុណភាពខុសៗគ្នា ពីគ្រួសារមួយទៅគ្រួសារមួយទៀត និងពុំមាននិរន្តភាពក្នុងការផ្គត់ផ្គង់ទៀងទាត់តាមតម្រូវការទីផ្សារ ក៏ដូចជារោងចក្រកែច្នៃ ។

ផលដែលនាំចេញ នៅជាវត្ថុធាតុដើម លក់ក្នុងតំលៃទាបពេក ដែលគួរត្រូវកែច្នៃជាមុន មុននឹងនាំចេញដើម្បីបានតំលៃបន្ថែម និងមានកំរៃខ្ពស់ ហើយដែលជាឱកាសផ្តល់ការងារធ្វើដល់ប្រជាពលរដ្ឋរកប្រាក់ចំណូលបន្ថែមសំរាប់គ្រួសារ និងផ្តល់ពន្ធអាករជូនរដ្ឋ ។

ខ្ញុំសង្កេតឃើញថា ធនធានមនុស្សដែលមានបច្ចេកវិទ្យាកែច្នៃជាម្ហូបអាហារបែបនេះ នៅខ្វះខាត និងខ្វះខាតសម្ភារៈ ដើមទុន និងពុំមានអ្នកវិនិយោគកែច្នៃកសិផលនេះនៅឡើយ ។

យើងទាំងអស់គ្នាត្រូវតែជួយជម្រុញការងារនេះឱ្យទទួលបានជោគជ័យ ព្រោះវាមិនត្រឹមតែជួយលើកកម្ពស់ជីវភាពគ្រួសារនៃប្រជាពលរដ្ឋយើងប៉ុណ្ណោះទេ ថែមទាំងជួយសំរាលសំពាធ អាជីវកម្មលើធនធានធម្មជាតិ និងជួយធ្វើឱ្យកាន់តែប្រសើរឡើងនូវការគ្រប់គ្រងធនធានធម្មជាតិ ដ៏មានសារៈសំខាន់ចំពោះជាតិថែមទៀតផង ។

**អង្គទេសិការគម្ពីរ ជាទីមេត្រី!**

ធនធានជលផល នៅក្នុងប្រទេសយើង បានចូលរួម នៅក្នុងការផ្តល់នូវប្រាក់ចំណូលមួយផ្នែក ទៅដល់ ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។

វិស័យនេះ ជាប្រភពចំណូលដ៏សំខាន់ និងមាននិរន្តភាពខ្ពស់ សម្រាប់គ្រួសារប្រជាពលរដ្ឋដែលរស់នៅតាមបណ្តាខេត្តជាប់ដងទន្លេ ។

បើយើងគិតដោយផ្ទាល់ គឺមានប្រជាពលរដ្ឋជាង១លាននាក់ បាននឹងកំពុងតែទទួលផលប្រយោជន៍ពីវិស័យមួយនេះ តែបើយើងគិតជាប្រយោល ឬជារួមវិញគឺមានប្រជាពលរដ្ឋរហូតដល់ជាង ២,៣ លាននាក់ ដែលរស់នៅអាស្រ័យលើធនធានជលផល ។

ធនធានជលផល រួមទាំងធនធានធម្មជាតិក្នុងទឹក មួយចំនួនទៀត បានដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាប្រព័ន្ធបរិស្ថាន និងបានរួមចំណែកទៅដល់វិស័យទេសចរណ៍ធម្មជាតិ (Eco-Tourism) របស់ប្រទេស។

ជាក់ស្តែង នាពេលបច្ចុប្បន្ននេះ ទិន្នផលត្រីទឹកសាបមានការកើនឡើងគួរឱ្យកត់សម្គាល់បើប្រៀបធៀបទៅនឹងបណ្តាឆ្នាំមុនៗ។

ការកើនឡើងនូវទិន្នផលត្រីក្នុងឆ្នាំនេះ គឺដោយសារកាខិតខំប្រឹងប្រែង និងកំណែទម្រង់វិស័យជលផលរបស់រាជរដ្ឋាភិបាល និងមន្ត្រីជលផល ក្នុងការកាត់បន្ថយចំនួនឡូតិ៍នេសាទជាលក្ខណៈ ឯកជនឱ្យទៅជាឡូតិ៍នេសាទជាលក្ខណៈសហគមន៍ និងឡូតិ៍បំរុងទុក។

ប៉ុន្តែទោះបីជាទិន្នផលត្រីមានការកើនឡើង បូករួមនឹងការកើនឡើងនៃប្រភេទត្រីមួយចំនួនទៀតក៏ដោយ ក៏សហគមន៍នេសាទមួយចំនួននៅតែជួបប្រទះ បញ្ហាជាពិសេស ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ និងការរំលោភបំពាន របស់អ្នកមានអំណាច និងឈ្មួញធំៗមួយចំនួនទៅលើសិទ្ធិ និងដែនការពាររបស់សហគមន៍នេសាទ។

ជាមួយគ្នានេះ ខ្ញុំយល់ថាយើងទាំងអស់គ្នាបានដឹងរួចហើយពីសារៈសំខាន់ និងសក្តានុពលនៃវិស័យជលផល។

វាជាការចាំបាច់ណាស់ ដែលព្រះរាជាណាចក្រកម្ពុជាយើងត្រូវតែមានច្បាប់ស្តីពីជលផលដើម្បីអនុវត្ត និងការពារថែរក្សាវិស័យនេះឱ្យបានគង់វង្សយូរអង្វែង ជាកេរមរតកទុកឱ្យកូនចៅជំនាន់ក្រោយដែលលោកត្រូវការធនធានជលផលដូចយើងដែរ ហើយត្រូវការច្រើនជាងយើងទៀតផង។

បច្ចុប្បន្ន រាជរដ្ឋាភិបាល តាមរយៈក្រសួងកសិកម្មបានធ្វើ និងផ្ញើសេចក្តីព្រាងច្បាប់ស្តីពីជលផលដល់រដ្ឋសភាហើយ ហើយគណៈកម្មការទី៣ នៃរដ្ឋសភា ដែលមានខ្ញុំជាប្រធានបានពិនិត្យ និងពិភាក្សាជាមួយជំនាញក្រសួងកសិកម្ម ហើយនឹងដាក់ឆ្លងសភាពេញអង្គដើម្បីអនុម័តក្នុងពេលឆាប់ៗនេះ។

ទន្ទឹមនឹងនេះដែរ សមាជិកា សមាជិកទាំងអស់ នៃព្រឹទ្ធសភា និងរដ្ឋសភា នាពេលកន្លងមកបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ផ្តល់ការគាំទ្រក្នុងការអនុម័តច្បាប់មួយចំនួន ដែលទាក់ទងនឹងការការពារធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន ហើយខ្ញុំមានជំនឿថា ទ្រង់ លោកជំទាវ ឯកឧត្តម នឹងផ្តល់នូវការខិតខំប្រឹងប្រែងនឹងគាំទ្រកាន់តែខ្លាំងថែមទៀត ដល់ការអនុម័តច្បាប់ និងសកម្មភាពលើកស្ទួយធនធានធម្មជាតិរបស់យើងទៅអនាគត។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលត្រូវតែបន្តពង្រឹង និងកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិស័យជលផលនេះឱ្យបានកាន់តែប្រសើរ និងអនុវត្តឱ្យបានជោគជ័យដើម្បីធានានូវនិរន្តភាពធនធានធម្មជាតិទាំងនេះ។

នៅទីបញ្ចប់ ខ្ញុំសូមឆ្លៀតឱកាសនេះ អំពាវនាវដល់រាជរដ្ឋាភិបាល ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ បណ្តាប្រទេសនានា និងបណ្តាអ្នកពាក់ព័ន្ធទាំងអស់ មេត្តាជួយផ្តល់នូវការឧបត្ថម្ភគាំទ្រយ៉ាងពេញទំហឹង ដល់វិស័យកសិកម្មដ៏មានសារៈសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យរីកចំរើន និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ។

ខ្ញុំមានជំនឿថា ទាំងអស់គ្នារួបរួមគ្នា យើងអាចធ្វើឱ្យប្រែក្លាយក្តីស្រម៉ៃ នៃក្តីសង្ឃឹមអនាគតល្អរុងរឿង ចាកផុតពីភាពខ្វះខាត នៃបងប្អូនជនរួមជាតិដ៏អភ័ព្វនៃយើងឱ្យក្លាយទៅជាការពិតជាក់ស្តែង។

ខ្ញុំសូមគោរពជូនពរ លោកជំទាវ ឯកឧត្តម លោកស្រី លោក ឱ្យជួបប្រទះតែនឹង សុភមង្គល និងការរីកចំរើនគ្រប់ពេលវេលា ហើយខ្ញុំសូមជូនពរ អង្គកិច្ចពិភាក្សាតុមូល ដ៏មានខ្លឹមសារ និងសារៈសំខាន់នាថ្ងៃនេះឱ្យទទួលបានជោគជ័យធំធេង។

ក្នុងនាមគណៈអធិបតី និងអង្គសន្និបាត ខ្ញុំសូមប្រកាសបើកជាផ្លូវការនូវកិច្ចពិភាក្សាតុមូលចាប់ពីពេលនេះតទៅ។

**សូមអរគុណ !**